**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមេសា ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមេសានេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមេសា ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែមេសាឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលបញ្ចប់ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងបញ្ចប់

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៤០ ២៣២ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៦០៧ហ.ត ស្មើនឹង០,២៥% និងដោយគ្រឿងយន្តចំនួន ៦៣៨ ៦២៥ហ.ត ស្មើនឹង៩៩,៧៥%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត តិចជាងឆ្នាំមុន ១០ ៤០១ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំងបញ្ចប់

-ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៦៣៨ ៣០៥ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៩៣៧ ២១៩តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦០២តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំងបញ្ចប់

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៧ ០២២ហ.ត ស្មើនឹង១០៣,៥៣% នៃផែនការចំនួន ៣៥ ៧៦០ហ.ត តិចជាងឆ្នាំមុន ៣ ៣៦៦ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១០៧ ៤០៦ហ.ត ស្មើនឹង១១៩,៥៩% នៃផែនការចំនួន ៨៩ ៨១០ហ.ត លើសឆ្នាំមុន ១៩ ៣៦៥ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726.128 / 726 129. Fax: (855) 23-217 320

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

ការនាំចេញអង្ករក្នុងខែមេសា ឆ្នាំ២០២២ មានចំនួន ៥០ ៥៩៩តោន កើនឡើងចំនួន ១១ ៧៩២តោន (៣០,៣៩%) បើធៀបនឹងខែមេសា ឆ្នាំ២០២១ ដែលមានចំនួន ៣៨ ៨០៧តោន។

បរិមាណអង្ករនាំចេញក្នុងរយៈពេល៤ខែដើមឆ្នាំ២០២២ មានចំនួន ២២១ ១៣៨តោន កើនឡើងចំនួន ២៨ ៦៤៣តោន (១៤,៨៨%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៤ខែដើមឆ្នាំ២០២១ ដែលមានចំនួន ១៩២ ៤៩៥តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ១៥០ ៧១៩តោន ស្មើនឹង ៦៨,១៦% អង្ករសគ្រប់ប្រភេទមានចំនួន ៦៨ ០៥១តោន ស្មើនឹង ៣០,៧៧% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ២ ៣៦៨តោន ស្មើនឹង ១,០៧%។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២២ប្រទេសមានបរិមាណសរុបចំនួន ៦៣ ៣៣៩តោន (កើនឡើងចំនួន ២០ ៨៨៩តោន ស្មើនឹង ៤៧,៨២%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១១៥ ២៥៥តោន (កើនឡើងចំនួន ១០ ៤៩៩តោន ស្មើនឹង ១០,០២%) ទិសដៅអាស៊ានចំនួន ៤ប្រទេសមានបរិមាណសរុបចំនួន ២១ ៨៧៦តោន (កើនឡើងចំនួន ៤ ៣៩៣តោន ស្មើនឹង ២៥,១៣%) និងទិសដៅដទៃទៀត២២ប្រទេសមានបរិមាណសរុប ២០ ៦៦៨តោន (ថយចុះចំនួន ៦ ៧៣៨តោន ស្មើនឹង -២៤,៥៩%) ។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៤៨ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ១៥៧ ២៥៩តោន (៧១,១១%) និងក្រុមហ៊ុន៣៨ដទៃទៀតបាននាំចេញត្រឹមតែ ៦៣ ៨៧៩តោន (២៨,៨៩%)។

### ១.៤.២ ការនាំចេញស្រូវ

ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ១ ៦៤៨ ៤៧៤តោន ទៅកាន់ប្រទេស វៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ០៧៦ ៦២៥តោន) មានការកើនឡើងចំនួន ១១៩ ១៩៤តោន (៧,៧៩%) បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២១ ដែលមានចំនួន ១ ៥២៩ ២៨០តោន។។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ មានចំនួន ២ ៧៦២ ៥៦៣,៧៥តោន ថយចុះចំនួន ៥៤ ៩២១,៦០តោន ស្មើនឹង -១,៩៥% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ដែលមានចំនួន ២ ៨១៧ ៤៨៥,៣៥តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៣៧១ ៥៩០ តោន (កើនឡើងចំនួន ១៦,៥៣%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ០១២ ៨០០តោន និងប្រទេសវៀតណាមចំនួន ៣៥៨ ៧៩០តោន

- ដំឡូងមីស្រស់មានចំនួន ៤១១ ៧០០តោន (កើនឡើងចំនួន ៣៣,៧៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៣០ ៥០០តោន និងប្រទេសថៃចំនួន ៨១ ២០០តោន

- ម្សៅដំឡូងមីមានចំនួន ៣២ ៤៩៦តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៣១ ៩១៧តោន សហរដ្ឋអាមេរិកចំនួន ៤០៨តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន និងប្រទេសអ៊ីតាលីចំនួន ១៩តោន

- កាកសំណល់ដំឡូងមីមានចំនួន ៦ ៥៨៩,៣៩តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៦ ០៨៩,៣៩ និងប្រទេសវៀតណាមចំនួន ៥០០តោន

- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៣៦៤ ៥៨៣,៦៧តោន (ថយចុះចំនួន -៤៧,៦០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៦៣ ២២១,៩៣តោន ប្រទេសថៃចំនួន ១ ២៥០តោន ប្រទេសឥណ្ឌាចំនួន ៩៨,១៦តោន និងប្រទេសចិនចំនួន ១៣,៥៨តោន

- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ២៤៤,៩៧តោន (ថយចុះចំនួន -៥៨,១៨%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១២៣,៣៨តោន ប្រទេសថៃចំនួន ៩២តោន ប្រទេសជប៉ុន ១៩,៧៩តោន និងកោះតៃវ៉ាន់ ៩,៨០តោន

- គ្រាប់ពោតមានចំនួន ៦០ ៥២៣,៧៦តោន (ថយចុះចំនួន -៥៤,៣១%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥៩ ៨៤០តោន កោះតៃវ៉ាន់ចំនួន ៦៧១,៤៦តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន

- គ្រាប់សណ្តែកបាយមានចំនួន ១០ ៧០០តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ៥៣ ៩៦០តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥១ ៧១០តោន និងប្រទេសថៃចំនួន ២ ២៥០តោន

- ផ្លែចេកស្រស់មានចំនួន ១៤០ ១៤០,៦៨តោន (ថយចុះចំនួន -១៥,៧១%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១២៨ ១៥៤,១០តោន និងប្រទេសវៀតណាមចំនួន ១២ ០២៦,៥៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៥ ៧៨០តោន (ថយចុះចំនួន -៧០,៣១%) នាំចេញទៅប្រទេសថៃ

- ផ្លែស្វាយស្រស់មានចំនួន ១០៤ ៩៥១,១០តោន (ថយចុះចំនួន -២៦,៣៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥៤ ៦៤៥,៦២តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសថៃចំនួន ២២ ៦៨១,១២តោន ប្រទេសកូរ៉េចំនួន ១៥៥,១៣តោន និងទីក្រុងហុងកុងចំនួន ១,៣៥តោន

- ដំណាប់ស្វាយមានចំនួន ៧ ២៤៩,៩៤តោន (ថយចុះចំនួន -១៣,៨៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៦ ៣៣២,៣២តោន ប្រទេសថៃចំនួន ៤២៨,៤៦តោន ប្រទេសហ្វីលីពីនចំនួន ២៣០,៥៣តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ៤២,៣៦តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៣,៩៧តោន និងប្រទេសអ៊ីតាលីចំនួន ២,៥២តោន

- ដូងប្រេងមានចំនួន ១៥ ៤៦០តោន (កើនឡើងចំនួន ០,៩៤%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ១៣ ៣០០តោន ប្រទេសម៉ាឡេស៊ីចំនួន ២ ០០០តោន និងប្រទេសថៃចំនួន ១៦០តោន

- ម្រេចមានចំនួន ៣ ៨៣៤,៦៧តោន (កើនឡើងចំនួន ៧៩,០៣%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣ ៥៤០,០១តោន ប្រទេសអាល្លឺម៉ង់ចំនួន ២៥៥,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ៨,៨០តោន ប្រទេសបារាំងចំនួន ៨,៦១តោន សាធារណរដ្ឋឆេកចំនួន ២,៣០តោន ប្រទេសជប៉ុនចំនួន ២,០១តោន ប្រទេសកាណាដាចំនួន ១តោន សហរដ្ឋអាមេរិកចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសស៊ុយអែតចំនួន ០,៤៩តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៩តោន និងប្រទេសអូស្ត្រាលីចំនួន ០,១០តោន

- ថ្នាំជក់មានចំនួន ១ ៣០០,៤១តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១ ២៤៥,៧០តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន និងប្រទេសហ្វីលីពីនចំនួន ១៥,១១តោន

- បន្លែចម្រុះមានចំនួន ៣២,១៥តោន (កើនឡើងចំនួន ១៨,៥០%) ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៣២,១១តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- និងផលិតផលចំនួន ៥៨មុខ ផ្សេងទៀតមានចំនួន ១៧១ ៣៨៧,០១តោន។

**១.៤.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ១ ៥៧២ ៩៨៥ ៧៤៧,៥៥ដុល្លារអាមេរិក ដែលក្នុងនោះៈ

- ការនាំចេញអង្ករមានចំនួន ១៨៩ ០៧២ ៩៩០ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ២៩៦ ៧២៥ ៣២០ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ១ ០៨៧ ១៨៧ ៤៣៧,៥៥ដុល្លារអាមេរិក។

## ២ ផ្នែកផលិតកម្មកៅស៊ូ

**២.១ ផ្ទៃដីកៅស៊ូ**

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

**២.២ ផលិតកម្មកៅស៊ូ**

- ផលិតផលជ័រកៅស៊ូរយៈពេល៣ខែសម្រេចបានចំនួន ៦០ ៩៤៨តោន កើនឡើងចំនួន ១ ១០៧តោន ស្មើនឹង២% ធៀបរយៈពេល៣ខែ ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូរយៈពេល៣ខែសម្រេចបានចំនួន ២ ៤០៣ម៣។

**២.៣ ការនាំចេញកៅស៊ូ**

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូរយៈពេល៣ខែសម្រេចបានចំនួន ៦១ ៨៣៩តោន កើនឡើងចំនួន ៧៨៣តោន ស្មើនឹង១% ធៀបរយៈពេល៣ខែ ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូរយៈពេល៣ខែសម្រេចបានចំនួន ២ ១៣០ម៣។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេល៣ខែ គឺ១ ៥៩៤ដុល្លារ/តោន បានថយចុះចំនួន ៤២ដុល្លារ/តោន ស្មើនឹង៣% ធៀបរយៈពេល៣ខែ ឆ្នាំ២០២១។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ ចំនួន ៥ផ្ទាំង និងបានចាត់បឋមសម្រាប់ចុះពិនិត្យជាក់ស្តែងនៅទីវាល

- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៤កន្លែង មានផ្ទៃដីព្រៃសរុបទំហំ ៥ ៥៤៧,៤៦ហ.ត

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុនចំនួន ៦ក្រុមហ៊ុនមានរណារយន្តចំនួន ៦៦គ្រឿង និងយានយន្តចំនួន ១១៣គ្រឿង មានក្រុមហ៊ុនខេមបូឌា ជន ផ្លេនថេសិន ខេត្តព្រះវិហារ ក្រុមហ៊ុនស៊ីងបាយអូរចេក ខេត្តក្រចេះ ក្រុមហ៊ុនសុវណ្ណភូមិ ខេត្តព្រះវិហារ ក្រុមហ៊ុនធីអេសអិម ខេត្តស្ទឹងត្រែង និងក្រុមហ៊ុនលឹមរ៉ូយ៉ាល់ ខេត្តមណ្ឌលគិរី

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន២ និងអ្នកស្នើសុំចំនួន ២នាក់ ដែលមានឈើហ៊ុបមូលចំនួន ១ ០០៩ម៣ កូនឈើចំនួន ១០ ២២៩ដើម អុស់ចម្រុះចំនួន ៥២០ស្ទែរ និងជ័រទឹកចំនួន ១០០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃនៅសហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ខេត្តក្រចេះ ដោយបានដំឡើងម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៣គ្រឿង ដើម្បីពិនិត្យ តាមដាន និងផ្ទៀងផ្ទាត់វត្តមានចំនួន និងប្រភេទនៃសត្វព្រៃដែលកំពុងរស់នៅ និងបន្តពូជនៅក្នុងតំបន់សហគមន៍ប្រាសាទទឹកខ្មៅ

- ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ១លើកនៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ ដោយបានដោះអន្ទាក់ខ្សែនីឡុងចំនួន ២៦ខ្សែ ចេញពីផ្លូវសត្វព្រៃឆ្លងកាត់

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៩ច្បាប់ ក្នុងនោះ ១៦ច្បាប់សម្រាប់ការថែរក្សាសត្វក្រចៅកកាំ និង៣ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ក្រចេះ និងខេត្តបាត់ដំបង

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៤ច្បាប់មានស្វាក្តាមចំនួន ១ ៩១៥ក្បាល សម្រាប់ដឹកជញ្ជូនទៅច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញចំនួន ១ ២៦០ក្បាល និងសម្រាប់ដឹកជញ្ជូនក្នុងស្រុកចំនួន ៦៥៥ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមសរុបចំនួន ១២៣ ៦៣៣ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៩ ៨៦១ក្បាល

- កំពុងថែរក្សាសត្វព្រៃចំនួន ១ ៧១៥ក្បាល (បក្សីចំនួន ៥៩ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)

- សង្គ្រោះសត្វព្រៃថ្មីចំនួន ៤៦ក្បាល ព្យាបាលចំនួន ៣៩ក្បាល និងបានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ២៥ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥ គឺអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង៩០៥ម៉ែត្រ និងជួសជុលទ្រុងសត្វព្រៃទំហំ៥៩ម៉ែត្រការ៉េ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយការពារចម្ការគ្រញូងសរុបប្រវែង ៥១ ៥៧៨ម៉ែត្រស្ថិតនៅក្នុងខេត្តកំពង់ធំ ព្រះសីហនុ ស្វាយរៀង និងខេត្តសៀមរាប

- ទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ៥សន្លឹកមានផ្ទៃដីសរុបទំហំ ៣៥៨,៦៦ហ.ត ក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៤៧ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហ.ត ចម្ការឈើដាំទំហំ ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពតកណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការថ្មីទំហំ៥១ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ

- ដាំឈើជាចម្ការថ្មីទំហំ ១ ៧៥០ហ.ត និងបណ្តុះកូនឈើចំនួន ២៥ ០០០ដើម និងបានបណ្តុះកូនឈើចំនួន ៥៣ ៧១០ដើម ក្នុងថ្នាលបណ្តុះកូនឈើចំនួន៦។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ១២០ករណី ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ២៣ករណី និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ៩៧ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់យាត់ និងដកហូតឈើមូល-ជ្រុងចំនួន ២ម៣ ឈើអារចំនួន ១០៩ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ១០០ក្បាល និង១០៤គ.ក្រ ផ្ទៃដីព្រៃឈើកាប់រានទំហំ ១ ២៤៧ហ.ត អនុផលព្រៃឈើ ឧបករណ៍ និងសម្ភារមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូល តែមួយ) ចំនួន ១កន្លែងស្ថិតក្នុងខេត្តតាកែវ និងពន្យារសុពលភាពចំនួន ១កន្លែងក្នុងខេត្តកំពង់ធំ

- ក្រុមហ៊ុនចំនួន៤នាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសចំនួន ៣៤៨ម៣ ជ័រទឹកចំនួន ២០តោន និងធ្យូងអាកាស្យាចំនួន ៣៩តោន

- ក្រុមហ៊ុនចំនួន១នាំចូលឈើកែច្នៃមានបរិមាណចំនួន ៤៨៥ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៤មានឈើកែច្នៃចំនួន ៩០៤ម៣ ចំណាំង កម្ទេចឈើប្រេងខ្យល់ចំនួន ៤ ៥០០តោន និងជ័រទឹកចំនួន ២០តោន

- ពន្យារគោលការណ៍នាំចេញជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃសរុបចំនួន ៨ ៧៩៩ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៣០១ ០០០ ៥៣៨រៀល និង២៣ ៤៨២,៤១ដុល្លារ។

## ៤ ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ២៨ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ១៩ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ០៩ករណី (បទល្មើស)។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១០០ ០៦៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះឃោសនាផ្សព្វផ្សាយដល់កសិករ និងអ្នកពាក់ព័ន្ធស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៥។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៦ក្បាល។

- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ២ ១១០វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ វត្ថុវិភាគចំនួន ៤មានប្រភពមកពីភូមិត្រពាំងរុន ឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប វិជ្ជមានH9N2 និងវត្ថុវិភាគចំនួន ២វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSD) មានប្រភពមកពីភូមិត្រេង ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង និងភូមិក្រពើគម ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានត្រឹមខែមីនាចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៧ ៧០០តោន សរុបរយៈពេល៤ខែចំនួន ៥៧ ៧០០តោន ស្មើនឹង ១៩,២៣% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៣៩ ៨០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៤ ០០០តោន សរុបរយៈពេល៤ខែចំនួន ១៣ ៣០០តោន ស្មើនឹង ៩,៥០% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ២ ៩០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១០ ២០០តោន សរុបរយៈពេល៤ខែចំនួន ៣៦ ៣០០តោន ស្មើនឹង២៧,៩២% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបមេសា ឆ្នាំ២០២១ កើនឡើងចំនួន ៤០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៦ ៤១០តោន សរុបរយៈពេល៤ខែចំនួន ១៦ ៦៧០តោន ស្មើនឹង៤,៦៣% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៨០ ៤៣០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៦ ៧០០ក្បាល សរុបរយៈពេល៤ខែចំនួន ៣២ ៥០០ក្បាល ស្មើនឹង១០,៨៣% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ២ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៣ ៨០០ ០០០កូន សរុបរយៈពេល៤ខែចំនួន ៥១ ៣០០ ០០០កូន ស្មើនឹង១៧,១០% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ៧០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ២ ៧០០តោន សរុបរយៈពេល៤ខែចំនួន ១៦ ៣០០តោន ស្មើនឹង២០,៣៨% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៧១០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ០៧០តោន សរុបរយៈពេល៤ខែចំនួន ៣ ៨០០តោន ស្មើនឹង៣១,៦៧% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៣២០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤ ០០០ ០០០លីត្រ សរុបរយៈពេល៤ខែចំនួន ១៥ ៥០០ ០០០តោន ស្មើនឹង៣១% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ១ ៤៥០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៣៤៧ករណី ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ១០៤ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៩៩ករណី និងសមុទ្រចំនួន ៤៨ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១០៦តោន សរុបរយៈពេល៤ខែចំនួន ៥២១តោន ស្មើនឹង៦,៥១% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ៥៧៦តោន

- ផលនេសាទកែច្នៃនាំចេញពុំមាន សរុបរយៈពេល៤ខែចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែមេសា ឆ្នាំ២០២១ ថយចុះចំនួន ១០៦តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ២១៤ ៣៩៦ ៨២៨រៀល សរុបរយៈពេល៤ខែចំនួន ៣៨៥ ០៨៤ ៧០៣រៀល ស្មើនឹង១០៧,២១% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបខែមេសា ឆ្នាំ២០២១ កើនឡើងចំនួន ៤១ ១៩៨ ៨៥៩រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១០៨ករណី លើវិស័យព្រៃឈើ២៧ករណី ជលផល៣៩ករណី សុខភាពសត្វនិងផលិតកម្មសត្វ៧ករណី កៅស៊ូ៣ករណី ក្សេត្រសាស្ត្រ១ករណី និងវិស័យផ្សេងៗ ៣១ករណី

- ចូលរួមប្រជុំទូទៅចំនួន ៩លើក និងសិក្ខាសាលា៤លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦០៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៤០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៦២ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១០៤ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១៧១ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរចំនួន ២៥ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២២ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែមេសា

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្ដាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៩លើក មានសមាជិកចូលរួមចំនួន ៤៣៧នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ១លើក មានសមាជិកចូលរួមចំនួន ១៥នាក់

- រៀបចំពិធីចុះហត្ថលេខាចំនួន ១លើក មានអ្នកចូលរួមសរុបចំនួន ៦០នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ១លើក មានសមាជិកចូលរួមចំនួន ១៥នាក់

- សរុបការរៀបចំកិច្ចប្រជុំ និងការទទួលភ្ញៀវមានចំនួន ១១លើក មានសមាជិកចូលរួមចំនួន ៤៦៧នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩០៨នាក់ (ស្រី១ ៤៥៩នាក់ ស្មើនឹង២៤,៧០%) រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩៦៦នាក់ (ស្រី៨៥១នាក់ ស្មើនឹង២៨,៧០%)

+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៤២នាក់ (ស្រី៦០៨នាក់ ស្មើនឹង២០,៦៦%)

- រៀបចំប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៥នាក់ និងទៅក្រៅក្រសួង ចំនួន ១នាក់

- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកចំនួន ២នាក់ ក្នុងនោះ ច្បាប់ឈប់សម្រាកពិសេសចំនួន ១នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២១២នាក់ (ស្រី៨៥នាក់) ក្នុងនោះ៖

+ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២១០នាក់ (ស្រី៨៥នាក់)

+ ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ២នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំសំណើសុំបន្ថែមសមាសភាពក្រុមការងារបច្ចេកទេសរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ

- ពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ បន្ទាប់ពីបានចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ និងបានបញ្ជូនរបាយការណ៍នេះជូនទៅក្រសួងផែនការ

- រៀបចំសមាសភាពចំនួន ៥រូបដើម្បីចូលរួមក្នុងក្រុមការងារអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥

- ចុះពិនិត្យការផ្គត់ផ្គង់ធាតុចូលផលិតកម្មមាន់ដល់អ្នកទទួលផលគម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ-១៩

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ញាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០២២-២០២៦។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣ ៤៣០លានរៀល

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៩ ៧១១លានរៀល

- រៀបចំសំណើសុំអនុញ្ញាតនាំចូលដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋនូវឧបករណ៍វិភាគដីម៉ាក Bruker ALPHA II Compact FT-IR Spectrometer ចំនួន ១កញ្ចប់មានទម្ងន់សរុប១០គ.ក្រ ជាអំណោយរបស់មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិអូស្ត្រាលី(ACIAR)

- ចុះពិនិត្យ និងប្រមូលចំណូលថ្លៃដីសម្បទានសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន ១២ក្រុមហ៊ុន ស្ថិតក្នុងខេត្តឧត្តរមានជ័យ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តព្រះវិហារ

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ២៣ក្រុមហ៊ុន

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២១ របស់រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ អគ្គនាយកដ្ឋានកៅស៊ូ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង និងខេត្តសៀមរាប។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ៩សវនដ្ឋាន ស្មើនឹង២៣,០៧% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន២៦អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០,៧៩%នៃផែនការចំនួន៥៦%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ទទួលជួបពិភាក្សាការងារជាមួយអង្គការអន្តរជាតិ១លើក និងវិស័យឯកជន១លើក
- ចូលរួមសិក្ខាសាលា១លើក សន្និសីទ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគីលើការងារក្រៅប្រទេស
- ចូលរួមកិច្ចប្រជុំ២លើកក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- សម្របសម្រួលរៀបចំកិច្ចប្រជុំដោយផ្ទាល់៧លើក
- សម្របសម្រួលលិខិតសុំផ្តល់មតិយោបល់ធាតុចូលលើសេចក្តីព្រាងឯកសារផែនការសកម្មភាពប្រចាំឆ្នាំនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (២០២៣-២០២៧)
- សម្របសម្រួលលិខិតអន្តរាគមន៍ទៅក្រសួងកសិកម្មហ្វីលីពីន ដើម្បីបន្តសុពលភាពអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មរវាងក្រសួងកសិកម្មហ្វីលីពីន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំសិក្ខាសាលាស្តីពីការបង្ហាញពីការគាំទ្ររបស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ក្នុងវិស័យកសិកម្ម និងការផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់នាំចេញផ្លែឈើស្រស់ទៅកាន់ប្រទេសចិន
- ចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើដំណាំឧស្សាហកម្មចេករវាងកម្ពុជា-ចិន
- ចុះអនុស្សរណៈនៃកិច្ចព្រមព្រៀង (MoA) ស្តីពីកិច្ចសហប្រតិបត្តិការកម្មវិធីកសិករតាមរដូវកាលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខេត្ត Yanggu របស់កូរ៉េ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការិយាល័យអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១១ក្រុមហ៊ុន។

### ១៣.២ ការិយាល័យមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៥៩សំណាក។

### ១៣.៣ ការិយាល័យអភិវឌ្ឍបទដ្ឋានគតិយុត្ត

- រៀបចំករណីសំណើសុំពិនិត្យ និងសម្រេចលើសេចក្តីព្រាងប្រកាសស្តីពីបញ្ជីថ្នាំកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តត្បូងឃ្មុំ។

### ១៣.៤ ការិយាល័យអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន ១៩៨ព័ត៌មាន
- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ៣៦៣ព័ត៌មាន

- ចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកប្រាសាទបល្ល័ង្កនៃខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្មស្ថិតនៅក្នុងភូមិសាស្ត្រឃុំសាលាវិស័យ

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋាន-កិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៩ក្បាល/ច្បាប់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះទៅថត Video បទយកការណ៍ចំនួន ៣ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ១ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៥ប្រធានបទ
- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំលេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ១៨ប្រធានបទ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ១១សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសចិញ្ចឹមមាន់ គោ ពពែ ត្រី ជំងឺលើដំណាំក្រូចឆ្មា និងដំណាំផ្សិត មកពីខេត្តកំពង់ធំ ស្វាយរៀង សៀមរាប ព្រៃវែង កណ្តាល និងខេត្តកំពង់ចាម។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ១៣២កិច្ចសន្យាគិតត្រឹមខែមេសា ឆ្នាំ២០២២ រួមមាន៖ ខេត្តពោធិ៍សាត់មាន៥កិច្ចសន្យា ស្ទឹងត្រែងមាន៧កិច្ចសន្យា តាកែវមាន១កិច្ចសន្យា មណ្ឌលគិរីមាន១កិច្ចសន្យា កំពង់ស្ពឺមាន២៨កិច្ចសន្យា កែបមាន៤កិច្ចសន្យា កណ្តាលមាន៥កិច្ចសន្យា ព្រះវិហារមាន១កិច្ចសន្យា ត្បូងឃ្មុំមាន១៩កិច្ចសន្យា សៀមរាបមាន ១១កិច្ចសន្យា កំពង់ចាមមាន៤កិច្ចសន្យា ស្វាយរៀងមាន៣កិច្ចសន្យា បន្ទាយមានជ័យមាន១៥កិច្ចសន្យា ក្រចេះមាន ១៤កិច្ចសន្យា កំពង់ធំមាន២កិច្ចសន្យា និងខេត្តកំពង់ឆ្នាំងមាន១២កិច្ចសន្យា
- ចុះសិក្សាគុណភាពគ្រាប់ស្វាយចន្ទីស្រស់ ដើម្បីទទួលធាតុចូលក្នុងការរៀបចំសេចក្តីព្រាងស្តង់ដារគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ កំពង់ចាម ព្រះវិហារ និងខេត្តរតនគិរី
- ចុះរៀបចំឯកសារពាក់ព័ន្ធនឹងស្តង់ដារ HACPP និងសម្របសម្រួលក្នុងការធ្វើសវនកម្មពីស្ថាប័នខាងក្រៅដើម្បីស្នើសុំវិញ្ញាបនបត្រ HACPP នៅសិប្បកម្មកែច្នៃស្វាយចន្ទីជ័យសំបូរ ខេត្តកំពង់ធំ
- បាននិងកំពុងសិក្សាស្រាវជ្រាវឯកសារបន្ថែមដែលពាក់ព័ន្ធនឹងនីតិវិធីនៃការអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បាននិងកំពុងសិក្សាគម្រោងធ្វើឱ្យប្រសើរឡើងនូវច្រវាក់តម្លៃផលិតផលកសិកម្មក្នុងប្រទេសកម្ពុជា (Improvement of Agricultural Value Chain in Cambodia) ក្នុងគោលបំណងលើកកម្ពស់ចំណូលប្រជាជនជនបទ បង្កើនគុណភាព និងបរិមាណគុណភាពកសិកម្មផ្សារភ្ជាប់ទីផ្សារ និងតម្លៃបន្ថែម
- វិភាគរកសមាសធាតុគីមី Moisture, Total Nitrogen, Organic Carbone, និង Phosphorous នៅក្នុងសំណល់លាមកសត្វពពែ សំណល់ស្មៅ និងផ្សិត
- វិភាគរកសមាសធាតុគីមី លោហៈធ្ងន់ អាសេនិច(As) បារត(Hg) សំណរ (Pb) និងកាឌីដ្យូម (Cd) នៅក្នុងអង្ករចំនួន ២ប្រភេទ
- វិភាគរកសមាសធាតុ កាកសរសៃ សំណើម ផេះ ខ្លាញ់ អាស៊ូត កាបូនហ្ស៊ីត្រាដ ប្រូតេអ៊ីន និងសារធាតុរ៉ែផ្សេងៗទៀតដូចជា កាល់ស្យូម ដែក សូដ្យូម ប៉ូតាស្យូម ម៉ាញ៉េស្យូម ផូស្វ័រ និង Aflatoxin នៅក្នុងអង្ករចំនួន ២ប្រភេទ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះពិនិត្យ និងជ្រើសរើសទីតាំងសម្រាប់ការងារពិសោធន៍នៅរដូវវស្សាឆ្នាំ២០២២ដែលប្រព្រឹត្តទៅនៅខេត្តត្បូងឃ្មុំ
- ចុះបណ្តុះបណ្តាលកសិករចំនួន ២៥នាក់នៅខេត្តកំពង់ចាម
- ចុះរៀបចំដាំដុះពិសោធន៍ដំឡូងមីនៅខេត្តព្រះវិហារ
- ចុះរៀបចំទីតាំងសម្រាប់ការងារពិសោធន៍ស្រាវជ្រាវនៅខេត្តព្រះវិហារ

- ចុះប្រមូលសមាសភាពចង្រៃលើដំណាំស្រូវនៅខេត្តកណ្ដាល ព្រៃវែង និងខេត្តតាកែវ
- ចុះវាស់វែងទិន្នន័យ និងប្រមូលផលពិសោធន៍ដំណាំដំឡូងមីនៅខេត្តព្រះវិហារ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- ដឹកនាំនិស្សិតឆ្នាំទី២ និងឆ្នាំទី៣នៃមហាវិទ្យាល័យកសិឧស្សាហកម្ម និងមហាវិទ្យាល័យវិស្វកម្មកសិកម្មចំនួន ៧០នាក់ ចុះទស្សនកិច្ចសិក្សានៅកសិដ្ឋានគោទឹកដោះគិរីស្វគ៌ ខេត្តតាកែវ
- រៀបចំសិក្ខាសាលាស្ដីពីការវាយតម្លៃគម្រោងប្លង់មេរៀនកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានការកែលម្អគោលការណ៍សរសេរសារណាបទ ព្រមទាំងការរៀបចំធ្វើគោលការណ៍ធ្វើតេស្តស្តង់ដារ និងការផ្តួចផ្តើមបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត គាំទ្រដោយគម្រោង HEIP
- ចុះវាយតម្លៃ និងវាស់វែងគុណភាពហ្គាសរបស់ប្រព័ន្ធចម្រោះជីវឧស្ម័ននៅកសិដ្ឋាន M's Pig I & II ដែលមានទីតាំងនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងកសិដ្ឋានចិញ្ចឹមជ្រូកចំនួន ២កន្លែងទៀត នៅខេត្តកំពង់ស្ពឺ ដើម្បីពិនិត្យមើលដំណើរការប្រព័ន្ធជីវឧស្ម័ន
- រៀបចំវេទិកាផ្សព្វផ្សាយចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានស្ដីពី ឱកាសនៃការផ្លាស់ប្តូរការសិក្សានៅវិទ្យាស្ថាន Oniris ប្រទេសបារាំងរយៈពេលខ្លី (៦ខែ) ក្រោមកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថាន Oniris ប្រទេសបារាំង ដោយសាស្ត្រាចារ្យបណ្ឌិត Lionel Boillereaux
- ចូលរួមវគ្គបណ្តុះបណ្តាលស្ដីពីបច្ចេកទេសចម្រាញ់យកសារធាតុ សេរីស៊ីន (Sericin) ចេញពីសម្បុកសូត្រសម្រាប់ផលិតធ្វើគ្រឿងសំអាង។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ៧៣៨នាក់ (ស្រី៤៧៨នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដីផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងសៀងនិងភាសាអង់គ្លេស
- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្ដោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្មៅ អាហារ ថ្នាំសត្វល្អិត និងជី
- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន
- ចុះតាមខេត្តដើម្បីពិនិត្យទីតាំងសិក្សាស្រាវជ្រាវចំនួន ១៥លើក។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្មក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ
- ចុះស្រង់ទិន្នន័យជំងឺប្រផេះ (oidium leaf disease) និងវាស់ទំហំដើមកៅស៊ូនៃចម្ការពិសោធន៍ក្លូន MK.AA.01 នៅខេត្តមណ្ឌលគិរី
- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍
- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នា ដើម្បីលាបរំញោចតាមពិធីសាពិសោធន៍
- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)
- សហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF កម្ពុជា ត្រួតពិនិត្យ និងប្រមូលទិន្នន័យចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការប្រមូលផលទឹកជ័រ នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
- អនុវត្តការថែទាំកៅស៊ូគ្រប់ចម្ការពិសោធន៍ (កាត់ខ្នែងកូនកៅស៊ូ ជំរះស្មៅតាមរង)
- បាញ់ថ្នាំDithan M45 និងដាក់ជីបំប៉នកូនកៅស៊ូនៅចម្ការដាំ២០២០-២០២១
- ត្រួតពិនិត្យបច្ចេកទេសការបើកមុខចៀរជ័រចម្ការថ្មី និងការក្រិតកំណត់សំបកចៀរជ័រ
- អនុវត្តការងារមន្ទីរពិសោធន៍តាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) សរុបចំនួន ៦សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៦៣៨ ៣០៥ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៩៣៧ ២១៩តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៦០២តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេស

កសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងប៉ារ៉ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេច

លេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ ចន្ទ ១រោច ខែ ចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**